ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ សាសនា ព្រះមហាក្សត្រ

*****

**********

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៣៩　　　　នាមនាមប្រជារាស្ត្រខ្មែរ

ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២　　　　តុលាការកំពូល

**សាលដីកា**

លេខ: ៥០　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣

ចុះថ្ងៃទី១៧ខែធ្នូឆ្នាំ២០០៣　　　　ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅៈ

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គីមសាន ចៅក្រមរបាយការណ៍

៤- លោក រៀល មួន ចៅក្រម

៥- លោក ស៊ិន ឌឹម ចៅក្រម

**ក្រឡាបញ្ជី**

លោក សាន សុផាត

**តំណាងមហាអយ្យការ**

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០១"គ" ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៣៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការកំពូល ។

**<u>ចំបទ:</u>** មនុស្សឃាដដោយចេតនាគិតទុកជាមុនប្រព្រឹត្តិនៅភូមិព្រៃពង្រ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-១៩៩២ ។

១-ជនជាប់ចោទឈ្មោះផន ផល ហៅ កាម៉ែល (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ កើតនៅ ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល របររកស៊ីធ្វើប៉ូលីស ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិត្រពាំងព្រីង ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ ឆឹង ផន "ស" ម្តាយ ឈ្មោះឃឹម យូ "រ" ប្រពន្ធឈ្មោះលី រ៉េត មានកូន២នាក់ ។ ក្នុងឃុំ ។

២-ជនជាប់ចោទឈ្មោះទឹម សម្បត្តិ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិធំ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល. របររកស៊ីធ្វើយោធា ទីលំនៅសព្វថ្ងៃ ភូមិប្រាសាទ ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះទឹម រស់ "រ" ម្តាយឈ្មោះប៊ុន ភួង ប្រពន្ធឈ្មោះម្លូង សាម៉ន កូនគ្មាន ។ ក្រៅឃុំ ។

-មានមេធាវី លោកហ៊ាង ហុង

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះប៉ុក គុន ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិព្រៃពង្រ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល ។

៤-ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្តឹងសាទុក្ខ)

-តាមពាក្យបណ្តឹងចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៨ របស់ឈ្មោះប៉ុក គុន ប្តឹងពីឈ្មោះផន ផល ដែលបានបាញ់សម្លាប់ប្តីរបស់ខ្លួន កាលពីថ្ងៃទី១៩-១២-៩៨ វេលាម៉ោង១៩ និង៣០នាទីយប់ ឈ្មោះផន ផល បានមកឈរហៅប្តីរបស់ខ្លួននៅមុខផ្ទះចំងាយប្រហែល៦ម៉ែត្រ ពេលនោះប្តីខ្លួនចេញមកដោយមានកូនរបស់ខ្លួនឈ្មោះគុង ភ័ក្រ មើលពីក្នុងផ្ទះមកដែរ ជួនពេលនោះ កូនខ្លួនបានឮសូរគ្រាប់កាំភ្លើងចំនួន៦គ្រាប់ប្តីខ្លួនក៏ដួល ហើយកូនក៏ស្រែកឱ្យគេជួយព្រោះគេលបបាញ់ឪពុកខ្លួន ខណៈនោះពួកកូនខ្លួនដែលមានឈ្មោះគុង តេង. គុង ភ័ក្រ ហង់ ហ៊ីង និងគុង វ៉ាត បានរត់មកស្តាប់ឪពុកខ្លួនផ្តាំថា "ឈ្មោះផន ផល ហៅកាម៉ែល ហៅគាត់ចេញពីផ្ទះ ហើយបាញ់តែម្តង ។

-បានឃើញដីកាលើកលែងចោទប្រកាន់លេខ១៧ ដ.ក.ល.ច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាលដែលបានសំរេច :

១-លើកលែងចោទលើឈ្មោះទឹម សម្បត្តិ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន ។

២-លើកលែងចោទលើឈ្មោះប៊ុន រឿន ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន ។

-បានឃើញដីកាលើកលែងចោទលេខ៧២ ដ.ក.ល.ច ចុះថ្ងៃទី២០-១០-២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាលដែលបានសំរេចៈ

-លើកលែងចោទប្រកាន់លើឈ្មោះផន ផល ហៅកាម៉ែល ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះប៉ុក គុន ប្តឹងមិនសុខចិត្តពីដីកាលើកលែងចោទប្រកាន់លេខ១៧ ដ.ក.ល.ច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាលត្រង់ចំណុចដីកាទាំងមូល ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តំណាងអយ្យការ អមតុលាការ

ខេត្តកណ្ដាល ប្ដឹងមិនសុខចិត្តពីដីកាលើកលែងចោទប្រកាន់លេខ៧២ ជ.ភ.ល.ច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្ដាលលើដីកាទាំងមូល ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា: សុំបដិសេធដីកាលើកលែងចោទប្រកាន់លេខ៧២ជ.ភ.ល.ច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ និងដីកាលើកលែងចោទប្រកាន់លេខ១៧ជ.ក.ល.ច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ របស់តុលាការខេត្តកណ្ដាល និងសុំឱ្យចោទប្រកាន់លើឈ្មោះផន ផល និងឈ្មោះទឹម សម្បត្តិ វិញ ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០១"គ" ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ របស់លោកព្រះរាជអាជ្ញាអមតុលាការខេត្តកណ្ដាល និងបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះប៉ុក កុន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់ដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្ដាលលេខ៧២ជ.ក.ល.ច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ ដែលប្ដឹងឧទ្ធរណ៍ដោយលោកព្រះរាជអាជ្ញា និងដីកាលើកលែងចោទប្រកាន់លេខ១៧ ជ.ក.ល.ច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ ដែលប្ដឹងឧទ្ធរណ៍ដោយឈ្មោះប៉ុក កុន ជាដើមបណ្ដឹងរដ្ឋប្បវេណី ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។ បើកផ្លូវប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០២ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្ដឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ០១"គ" ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសេចក្ដីសំរេច ។

-បានឃើញសារណា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០២ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ (ម្ចាស់បណ្ដឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៣ របស់ជនជាប់ចោទឈ្មោះទឹម សម្បត្តិ (ជាចុងបណ្ដឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា: រឿងនេះផ្អែកលើកត្តាសត្យានុម័តឃើញថា មានការគិតទុកជាមុនមនុស្សឃាតដោយចេតនាមានអ្នកជួលពិតប្រាកដ ។ ដូច្នេះសូមធ្វើការចោទប្រកាន់ជនល្មើសទាំងអស់វិញទៅ ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្ដាល ដើម្បីចាត់ការតាមច្បាប់ព្រមទាំងទុកជាមោឃៈដីកាលើកលែងចោទប្រកាន់ទាំងអស់ និងរុករកអ្នកជួលសំលាប់ក្នុងរឿងនេះឱ្យឃើញ។

- បានស្តាប់ក្រឡាបញ្ជីអានសេចក្តីសុំប្តឹងសាទុក្ខ និង សារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (ជាប្តាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

- បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង សារណាតបរបស់ឈ្មោះទឹម សម្បត្តិ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់ចំលើយអះអាងរបស់ឈ្មោះផន ផល (ជាចុងបណ្តឹងសាទុក្ខ) នាពេលសវនាការថា: ខ្ញុំបាទមិនបានចូលរួមប្រព្រឹត្តិអំពើល្មើសទេ ហើយមិនដែលស្គាល់គ្រួសារជនរងគ្រោះដែរ ចំលើយប៉ូលីសមានការបង្ខិតបង្ខំ ។ ខ្ញុំបាទពុំដឹងទេ ដឹងនៅពេលចាប់ ខ្ញុំបាទមកដល់ស្នងការ គេបង្ហាញរូបថតឱ្យខ្ញុំបាទមើល សូមតុលាការដោះលែង។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក គង់ ហេង ជាមេធាវីការពារជនជាប់ចោទឈ្មោះ ផន ផល (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា: តុលាការថ្នាក់ក្រោមដោះលែងជនល្មើសដ៏ទៃទៀត នៅសល់កូនក្តីខ្លួនតែម្នាក់ឯង ចំលើយនៅប៉ូលីសមានការគំរាមកំហែងកូនក្តីខ្លួនត្រូវបានលើកលែងចោទប្រកាន់តែព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ការប្តឹងនេះគឺថ្លោះសិទ្ធិហើយ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកហ៊ាង ហុង ជាមេធាវីការពារជនជាប់ចោទឈ្មោះទឹម សម្បត្តិ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា: កូនក្តីរបស់ខ្លួនមិនបានចូលរួមប្រព្រឹត្តិបទល្មើសទេ នៅថ្ងៃកើតហេតុឈ្មោះទឹម សម្បត្តិ នៅវត្តគៀនស្វាយ មានលោកតាទេព ផាន ជាសាក្សីព្រមទាំងមានការបញ្ជាក់ពីមេឃុំទៀតផង ។ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលនៅពេលជំនុំជំរះថា: រឿងនេះមុនពេលឪពុកស្លាប់ គាត់បានស្រែកប្រាប់កូនថា: អ្នកសំលាប់គាត់គឺឈ្មោះផន ផល ។ ម្យ៉ាងទៀតនៅប៉ូលីសជនជាប់ចោទឆ្លើយថាមានការគំរាមកំហែងតែមកដល់ចៅក្រមស៊ើបអង្កេតសរសេរចំលើយហើយឱ្យខ្លួនផិតមេដៃនោះ គឺពុំគួរឱ្យជឿបានឡើយ សូមតម្កល់ការសន្និដ្ឋានខាងលើទុកនៅដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់បណ្តឹងសាទុក្ខ និងសារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ចំលើយរបស់ជនជាប់ចោទឈ្មោះផន ផល សារណារបស់ទឹម សម្បត្តិ សេចក្តីសន្និដ្ឋានរបស់មេធាវីរបស់ឈ្មោះផន ផល និង សេចក្តីសន្និដ្ឋានរបស់មេធាវីរបស់ឈ្មោះទឹម សម្បត្តិ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០២ របស់ឯកឧត្តមអគ្គព្រះរាជ

អាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេច តម្កល់ដីកាលើកលែងចោទប្រកាន់លេខ៧២ ដកលច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ និងដីកាលើកលែងចោទប្រកាន់លេខ១៧ ដកលច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាលនោះ គឺជាការភ័ន្តច្រឡំពីព្រោះថា:

+នៅចំពោះមុខនគរបាលក៏ដូចជាចំពោះមុខចៅក្រមស៊ើបអង្កេតជនជាប់ចោទឈ្មោះផន ផល បានបញ្ជាក់ថា ខ្លួនជាអ្នកស្រែកហៅជនរងគ្រោះឱ្យចេញពីផ្ទះ ហើយអ្នកដៃដល់ដែលបាញ់ជនរងគ្រោះគឺឈ្មោះអឿន (ប៊ុន ពេញ)ឈ្មោះប៊ុន រឿន (ហ)វែង និងឈ្មោះទឹម សម្បត្តិ ។

+ដីកាលើកលែងចោទប្រកាន់ឈ្មោះទឹម សម្បត្តិ ឈ្មោះប៊ុន រឿន និងឈ្មោះផន ផល ពុំបានជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណីទេ ដែលជាការរំលោភទៅលើមាត្រា៩១នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ម្យ៉ាងទៀត ដីកាលើកលែងចោទប្រកាន់លើឈ្មោះប៊ុន រឿន និងលើឈ្មោះទឹម សម្បត្តិ ជាដីកាដាច់ដោយឡែកពីគ្នា ប៉ុន្តែចុះលេខ និងកាលបរិច្ឆេទដូចគ្នា ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍លើកយកតែបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់អ្នកស្រីប៊ុក កុន មកពិចារណាដោយពុំបានពិចារណាលើបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ របស់អ្នកស្រីប៊ុក កុន ផងនោះ គឺជាការភ័ន្តច្រឡំពីព្រោះថា :

+បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ ដែលត្រូវបានមហាអយ្យការ អមសាលាឧទ្ធរណ៍ទទួលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ហើយបញ្ជូនទៅឱ្យតុលាការខេត្តកណ្តាល ដើម្បីចាត់ឱ្យក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍នោះ អ្នកស្រីប៊ុក កុន បានប្តឹងពីដីកាលើកលែងចោទប្រកាន់លើឈ្មោះប៊ុន រឿន និងឈ្មោះទឹម សម្បត្តិ។

+បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ គឺក្រឡាបញ្ជីបានចុះបណ្តឹងឧទ្ធរណ៍ត្រង់ចំណុចតែលើកលែងចោទប្រកាន់លើឈ្មោះទឹម សម្បត្តិ តែម្នាក់ ។

-យល់ឃើញថា ចម្លើយរបស់ជនជាប់ចោទនៅចំពោះមុខនគរបាល ក៏ដូចនៅចំពោះមុខនៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា មានជនផ្សេងទៀត បានជួលជនល្មើសទាំង៣នាក់ឱ្យធ្វើឃាតជនរងគ្រោះប៉ុន្តែតំណាងអយ្យការ អមតុលាការខេត្តកណ្តាល ពុំបានផ្តើមចោទប្រកាន់លើជនទាំងនោះឡើយ ។

-យល់ឃើញថា មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះផន ផល,ទឹម សម្បត្តិ,ប៊ុន រឿន និងជនផ្សេងទៀត ដែលបានជួលជនទាំង៣នាក់ឱ្យធ្វើឃាតលើឈ្មោះភួង គុង ពីបទៈមនុស្សឃាតដោយចេតនា និងគ្រោងទុកជាមុន។

-យល់ឃើញថា ការដែលលោកមេធាវីជនជាប់ចោទលើកឡើងថា ភស្តុតាងដាក់បន្ទុកលើកូនក្តីរបស់លោកធ្វើឡើងដោយមានការក្លែងបន្លំ ហើយកូនក្តីរបស់លោកពុំបានចូលរួមក្នុងការប្រព្រឹត្តិបទល្មើសនេះទេ នោះពុំទាន់មានភស្តុតាងដោះបន្ទុកណាធ្ងន់ល្មមគួរឱ្យតុលាការជឿបានឡើយ ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះទឹម សម្បត្តិ បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមតាមការនោះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទទឹម សម្បត្តិ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០១"គ" ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះផន ផល**

**កំបាំងមុខជនជាប់ចោទឈ្មោះទឹម សម្បត្តិ ប៉ុន្តែចាត់ទុកជាចំពោះមុខ :**

១-ទទួលបណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០២ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ០១"គ" ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៣៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការកំពូលទៅអយ្យការអមតុលាការខេត្តកណ្តាល ដើម្បីអនុវត្តតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលេខ៣១១ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៩៩ នឹងធ្វើការផ្តើមចោទប្រកាន់លើឈ្មោះប៊ុន រឿន និងអ្នកជួលសំលាប់ជនរងគ្រោះ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣ ។